**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១៤ សលក

# សារលិខិត
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ផ្ញើជូនជនរួមជាតិកម្ពុជា
## ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

-សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជ សម្តេចព្រះរាជាគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ
-សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជាទីមេត្រី
-បងប្អូនជនរួមជាតិ ដែលកំពុងរស់នៅក្នុងនិងក្រៅប្រទេស ជាទីស្នេហា

ទូលបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមចូលរួមអបអរសាទរក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ដែលប្រព្រឹត្តទៅនាថ្ងៃចន្ទ ៦កើត ថ្ងៃអង្គារ ៧កើត ថ្ងៃពុធ ៨កើត និងថ្ងៃព្រហស្បតិ៍ ៩កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ទី១៤ ទី១៥ និងថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២០ ជាមួយបងប្អូនជនរួមជាតិទាំងអស់ដែលកំពុងរស់នៅក្នុងនិងក្រៅប្រទេស ប្រកបដោយក្តីសោមនស្សរីករាយ សិរីសួស្តី និងជ័យមង្គលដ៏ឧត្តុង្គឧត្តមក្នុងក្រុមគ្រួសារនិងសង្គមជាតិទាំងមូល។

ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ឆ្នាំនេះ ប្រព្រឹត្តទៅស្របពេលដែលរាជរដ្ឋាភិបាលបានខិតខំបន្តអនុវត្តកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ដែលបានដាក់ចេញកាលពីខែកញ្ញា ឆ្នាំ២០១៨ សម្រេចបានសមិទ្ធផលធំៗថ្មីៗយ៉ាងច្រើនប្រកបដោយមោទនភាព។

រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ដែលបានប្រសូតចេញពីការបោះឆ្នោត ប្រកបដោយភាពសេរី យុត្តិធម៌ ត្រឹមត្រូវ តម្លាភាព ស្របទៅតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនិងបានទទួលការគាំទ្រនិងជំនឿទុកចិត្តពីប្រជាពលរដ្ឋដ៏ច្រើនលើសលប់ កំពុងបន្តបេសកកម្មដ៏ឧត្តុង្គឧត្តមជាប្រវត្តិសាស្ត្ររបស់ខ្លួន ជាមួយនឹងការប្តេជ្ញាចិត្តយ៉ាងមុតមាំឥតរាថយនិងកាន់តែស្វាហាប់ជាងពេលណាៗទាំងអស់ក្នុងការបម្រើប្រជាជនទ្វេដង ក៏ដូចជាក្នុងការពន្លឿនកិច្ចអភិវឌ្ឍនិងជំរុញអនុវត្តការកែទម្រង់កាន់តែស៊ីជម្រៅនិងទូលំទូលាយក្នុងគ្រប់វិស័យប្រកបដោយឆន្ទៈមុតស្រួចនិងកាន់តែមានប្រសិទ្ធភាពតាមរយៈការ

ដាក់ចេញនូវផែនការសកម្មភាពថ្មីៗដ៏ម៉ត់ចត់និងប្រទាក់ក្រឡាគ្នាក្នុងចំណោមការដ្ឋានកំណែទម្រង់នានា ជាពិសេសកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ដែលបានជានាំនូវការលើកកម្ពស់អភិបាលកិច្ចល្អនៃស្ថាប័នរដ្ឋគ្រប់ថ្នាក់ ការផ្តល់សេវាសាធារណៈជូនប្រជាជន ការពង្រឹងយុត្តិធម៌និងសមភាពក្នុងសង្គម ការបង្កើនចំណូលថវិកាជាតិនិងការគ្រប់គ្រងចំណាយប្រកបដោយវិចារណភាព និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ឆ្ពោះទៅរកអនាគតមួយដ៏រុងរឿងស្របតាមឆន្ទៈនិងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជននៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ឆ្នាំចាស់ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ បានកន្លងផុតទៅ ដោយផ្លាស់ជំនួសវិញនូវឆ្នាំថ្មី ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ រាជរដ្ឋាភិបាលបន្តកសាងប្រទេសជាតិឱ្យមានវឌ្ឍនភាពលើគ្រប់វិស័យ និងការពារដាច់ខាតនូវឯករាជ្យជាតិ សន្តិភាព អធិបតេយ្យជាតិ និងបូរណភាពទឹកដី ការពារសមិទ្ធផលសង្គមជាតិ ទប់ស្កាត់ការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងកម្ពុជា ប្រឆាំងដាច់ខាតរាល់សកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងបដិវត្តន៍ពណ៌ ឬការញុះញង់ណាមួយដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញនិងគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ បង្កឱ្យមានអស្ថិរភាពនយោបាយឬចលាចលក្នុងសង្គមជាតិកម្ពុជា។ ជាលទ្ធផល កម្ពុជារក្សាបាននូវសុខសន្តិភាព ឯករាជ្យជាតិ និងអធិបតេយ្យភាពរបស់ខ្លួន ព្រមទាំងបញ្ចៀសបាននូវគ្រោះមហន្តរាយសម្រាប់ប្រជាជនកម្ពុជា ដែលកំពុងចូលរួមយ៉ាងសស្រាក់សស្រាំក្នុងជីវភាពរស់នៅប្រចាំថ្ងៃនិងកិច្ចអភិវឌ្ឍប្រទេសជាតិ។

ដោយឈរលើមូលដ្ឋានដែលប្រទេសជាតិមានសន្តិសុខ ស្ថិរភាពនយោបាយ និងសន្តិភាពពេញលេញនេះ ក្នុងឆ្នាំ២០១៩កន្លងទៅ តាមការប៉ាន់ស្មាន សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនខ្ពស់ប្រមាណ ៧,១%។ កំណើនដ៏រឹងមាំនេះ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការរីកចម្រើននៃវិស័យឧស្សាហកម្ម កម្មន្តសាលសំណង់ កសិកម្ម និងសេវាកម្ម ដូចជា ទេសចរណ៍និងអចលនទ្រព្យជាដើម។ គួរកត់សម្គាល់ថា កម្ពុជាកំពុងតែផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅជាប្រទេសដែលពឹងផ្អែកលើវិស័យឧស្សាហកម្មនិងសេវាកម្ម។ កម្ពុជាបានអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចប្រកបដោយភាពប្រុងប្រយ័ត្ន និងធ្វើឱ្យសេដ្ឋកិច្ចមានស្ថិរភាព ហើយបានជំរុញនិងលើកកម្ពស់ការធ្វើពិពិធកម្មសេដ្ឋកិច្ច ភាពប្រកួតប្រជែង ព្រមទាំងការផលិតនិងការប្រើប្រាស់ក្នុងស្រុក។ ទំហំពាណិជ្ជកម្មអន្តរជាតិមានប្រមាណជាង ៣៤ ៥៩៦លានដុល្លារអាមេរិក ចំណែកឯការនាំចេញមានប្រមាណជាង ១៤ ៩១៥លានដុល្លារអាមេរិក។ អត្រាប្តូរប្រាក់មានស្ថិរភាព អត្រាអតិផរណាស្ថិតក្នុងកម្រិតទាបនិងអាចគ្រប់គ្រងបាន ទុនបម្រុងអន្តរជាតិបានកើនជារៀងរាល់ឆ្នាំ អាស្រ័យដោយវិនិយោគផ្ទាល់ពីបរទេសមានកំណើនល្អនិងតុល្យភាពជញ្ជីងទូទាត់ក៏មានភាពកាន់តែប្រសើរឡើងដែរ។ រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការកែទម្រង់ឱ្យកាន់តែស៊ីជម្រៅនិងលើកទឹកចិត្តដល់អ្នកវិនិយោគឱ្យមកបោះទុននៅកម្ពុជាកាន់តែច្រើន ខណៈដែលយើងបានរៀបចំការសម្រួលពាណិជ្ជកម្ម ពង្រឹងភាពប្រកួតប្រជែងជូនវិនិយោគិននៅកម្ពុជា ក្រោមដំបូលសន្តិភាព លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដោយមិនមានការរើសអើង។

កម្រិតជីវភាពរបស់ប្រជាជនកាន់តែមានភាពល្អប្រសើរ ដែលបង្ហាញឱ្យឃើញតាមរយៈសូចនាករសង្គម ជាពិសេសការកើនឡើងនៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) ជាមធ្យមសម្រាប់មនុស្សម្នាក់ពី ១ ៥៤៨ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៨ ដល់ប្រមាណ ១ ៦៧៩ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩។ អត្រាភាពក្រីក្រ

ត្រូវបានកាត់បន្ថយមកក្រោម ១០% ក្នុងឆ្នាំ២០១៩ និងបន្តធ្លាក់ចុះថែមទៀតនៅឆ្នាំ២០២០នេះ។ ម្យ៉ាងទៀត កម្ពុជារក្សាបានសន្តិសុខការងារ ដោយអត្រាគ្មានការងារមានប្រមាណ ០,៣% ប៉ុណ្ណោះ ហើយគម្លាតនៃប្រាក់ចំណូលរបស់ប្រជាជន ក៏មានការធ្លាក់ចុះជាលំដាប់ផងដែរ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏បានរៀបចំបង្កើនប្រាក់ចំណូលជូនមន្ត្រីរាជការនិងកងកម្លាំងប្រដាប់អាវុធ ឱ្យទទួលបាននូវប្រាក់បៀវត្សកាន់តែខ្ពស់ពីមួយឆ្នាំទៅមួយឆ្នាំ ដែលក្នុងឆ្នាំ២០១៩កន្លងទៅ ប្រាក់បៀវត្សអប្បបរមារបស់មន្ត្រីរាជការនិងកងកម្លាំងប្រដាប់អាវុធបានកើនដល់កម្រិតជាង ១,១លានរៀល ហើយការបើកបៀវត្សបានធ្វើទាន់ពេលវេលាគឺបើក ២ដងក្នុងមួយខែ តាមប្រព័ន្ធធនាគារ។

ក្នុងឆ្នាំកន្លងទៅ រាជរដ្ឋាភិបាលសម្រេចបានការងារធំៗជាច្រើនវិស័យ ក្នុងនោះការកសាងហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ស្ពាន ត្រូវបានបន្តអនុវត្តជាប់ជាប្រចាំ ស្របតាមការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដើម្បីបម្រើដល់វិស័យដឹកជញ្ជូននិងការធ្វើដំណើររបស់ប្រជាជន។ រហូតមកដល់បច្ចុប្បន្ន សមិទ្ធផលជាច្រើនក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានរាជរដ្ឋាភិបាលសម្រេចបាន ក្នុងនោះមាន ផ្លូវជាតិ ផ្លូវខេត្ត ផ្លូវលំជនបទ ស្ពានឆ្លងកាត់ទន្លេ ស្ពានអាកាសក្នុងរាជធានីភ្នំពេញ។ល។ ជាក់ស្តែង ក្នុងឆ្នាំ២០១៩កន្លងទៅ រាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការមានជាអាទិ៍ ផ្លូវជាតិលេខ៧ មានប្រវែង៩៣,៧០គ.ម. ផ្លូវជាតិលេខ១៣ មានប្រវែង៦២,៤០គ.ម. ផ្លូវជាតិលេខ៥៣និងផ្លូវខេត្តលេខ១៥១B មានប្រវែង៧០,៦០គ.ម.។ ថ្មីៗនេះ មានការបើកការដ្ឋានស្ថាបនាផ្លូវល្បឿនលឿនពីភ្នំពេញទៅក្រុងព្រះសីហនុ មានប្រវែង១៩០,០១គ.ម. ក្រោមរូបភាពសាងសង់ ធ្វើអាជីវកម្ម និងផ្ទេរ (B.O.T.) ការបើកការដ្ឋានស្ថាបនាកំណាត់ផ្លូវជាតិលេខ២និងផ្លូវជាតិលេខ២២ មានប្រវែង៧២,១៧គ.ម. និងការបើកការដ្ឋានស្ថាបនាផ្លូវជាតិលេខ១០ មានប្រវែង១៩៨,៧២ គ.ម. ព្រមទាំងការដាក់ឱ្យដំណើរការផ្លូវជាតិលេខ៥៨ មានប្រវែង១៧៤,១៦គ.ម. និងផ្លូវជាតិលេខ៥៥ មានប្រវែង១៨២,១៦គ.ម.។

ចំពោះវិស័យថាមពលអគ្គិសនីវិញ នៅឆ្នាំ២០១៩កន្លងទៅ បរិមាណផ្គត់ផ្គង់ដោយវារីអគ្គិសនីនិងរោងចក្រអគ្គិសនីដុតធ្យូងថ្ម ដែលជាប្រភពថាមពលផ្ទាល់របស់កម្ពុជា សម្រេចបានជាង ១០ ៦២០លានគីឡូវ៉ាត់ម៉ោង បើធៀបនឹងឆ្នាំមុន ដែលមានជាង ៩ ៦៦០លានគីឡូវ៉ាត់ម៉ោង កើនឡើង ៩,៩៣%។ ការតភ្ជាប់ខ្សែបណ្តាញចរន្តឱ្យដល់ប្រជាពលរដ្ឋជាអ្នកប្រើប្រាស់ថាមពលអគ្គិសនីរហូតមកដល់ឆ្នាំ២០១៩នេះ ចំពោះគេហដ្ឋានប្រជាពលរដ្ឋសុទ្ធសាធ បានកើនដល់ប្រមាណ ២,៦៨លានខ្នងផ្ទះ ត្រូវជាប្រមាណ ៧៤,៧៨% នៃចំនួនផ្ទះសរុបប្រមាណ ៣,៥៧លានខ្នង និងគ្របដណ្តប់ដល់ភូមិប្រមាណ ៩២,៦៨% នៃចំនួនភូមិសរុប ១៤ ៣៩៤ភូមិ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ក្នុងឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ កន្លងទៅនេះដែរ ដោយសារអាកាសធាតុមានលក្ខណៈអំណោយផលល្អសម្រាប់ការបង្កបង្កើនផលដំណាំស្រូវនៅទូទាំងព្រះរាជាណាចក្រកម្ពុជា បានធ្វើឱ្យបរិមាណផលិតផលស្រូវរដូវវស្សានិងស្រូវរដូវប្រាំង សម្រេចបានប្រមាណជាង ១០,៨៨លានតោន គឺប្រហាក់ប្រហែលនឹងឆ្នាំ២០១៨ ដែលតាមការប៉ាន់ស្មាន យើងមានអតិរេកស្រូវជាង ៥,៧៦លានតោន គិតជាអង្ករស្មើនឹង ៣,៦៩លានតោន សម្រាប់បម្រើឱ្យការនាំចេញ។ រីឯការនាំចេញអង្ករទៅទីផ្សារបរទេសបានជាង ៦២ម៉ឺនតោន ទៅកាន់ទិសដៅ ៥៩ប្រទេស។

ហេតុមកដល់បច្ចុប្បន្ន នៅព្រះរាជាណាចក្រកម្ពុជា វិស័យឧស្សាហកម្មនិងសិប្បកម្មបានរីកលូតលាស់ជាបន្តបន្ទាប់។ រោងចក្រសរុបមានចំនួនជាង ១ ៧០០រោងចក្រ ដែលភាគច្រើនជារោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងមានឧស្សាហកម្មធុនតូចនិងមធ្យម និងសិប្បកម្មជាង ៥២ពាន់មូលដ្ឋាន ហើយដែលបានស្រូបកម្លាំងពលករសរុបប្រមាណជិត ២លាននាក់។ ស្របនឹងការរីកចម្រើនវិស័យឧស្សាហកម្មនិងសិប្បកម្ម រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើជីវភាពរស់នៅចំពោះកម្មករ និយោជិត ដោយបានដំឡើងប្រាក់ឈ្នួលអប្បបរមាជូនកម្មករ និយោជិត ផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងកើនឡើងដល់ ១៩០ដុល្លារអាមេរិក ហើយបើក២ដងក្នុងមួយខែ នៅឆ្នាំ២០២០ ដោយមិនទាន់គិតប្រាក់អត្ថប្រយោជន៍បន្ថែមផ្សេងៗទៀត ពីការអនុវត្តគោលនយោបាយជាតិគាំពារសង្គមរបស់រាជរដ្ឋាភិបាល។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានគិតគូរនិងដោះស្រាយជូនបងប្អូន និយោជិត កម្មករ កម្មការិនីនូវអត្ថប្រយោជន៍ជាច្រើនទៀតដូចជាការពិនិត្យសុខភាព ការព្យាបាលជំងឺដោយមិនគិតថ្លៃនៅតាមមន្ទីរពេទ្យរបស់រដ្ឋ ការផ្ដល់នូវរបបឧបត្ថម្ភមាតុភាពចំនួន ៤០ម៉ឺនរៀល សម្រាប់ការសម្រាលបានកូនមួយ តាមរយៈបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស.) ហើយបានដាក់ឱ្យអនុវត្តនូវការឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកូនអាយុក្រោម ២ឆ្នាំនៃគ្រួសារមានបណ្ណសមធម៌ឬបណ្ណអាទិភាព ដើម្បីសម្រាលបន្ទុក លើកកម្ពស់ជីវភាពនិងអាហារូបត្ថម្ភដល់ស្ត្រីនិងកុមារ និងបានបង្កើតមូលនិធិគន្ធបុប្ផាកម្ពុជា ដើម្បីផ្តល់ការគាំទ្រផ្នែកសុខភាពប្រកបដោយគុណភាពនិងមិនគិតថ្លៃដល់កុមារកម្ពុជា និងការធ្វើដំណើរតាមរថយន្តក្រុងសាធារណៈមិនគិតថ្លៃនៅពេលបុណ្យភ្ជុំបិណ្ឌនិងចូលឆ្នាំខ្មែរផងដែរ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏បាននិងកំពុងជួយពលករកម្ពុជាដែលធ្វើការនៅបរទេសមានប្រមាណជាង ៦ម៉ឺននាក់ មានជាអាទិ៍ ប្រទេសថៃ សាធារណរដ្ឋកូរ៉េ ម៉ាឡេស៊ី ជប៉ុន សិង្ហបុរី ហុងកុង និងប្រទេសអារ៉ាប៊ីសាអូឌីត ក្នុងការធានានូវផលប្រយោជន៍ស្របច្បាប់និងមុខជំនាញបច្ចេកទេស។

វិស័យសំណង់បាននិងកំពុងរីកលូតលាស់ ដោយមានអគារខ្ពស់ៗប្រមាណជាង ១ ៧០០អគារ ចាប់ពី៥ជាន់ ទៅ៤០ជាន់ឡើង ក្នុងរាជធានីភ្នំពេញ ខេត្តព្រះសីហនុ និងនៅតាមបណ្តាខេត្តមួយចំនួន។ ភ្ញៀវទេសចរអន្តរជាតិចូលមកព្រះរាជាណាចក្រកម្ពុជា មានចំនួនប្រមាណ ៦,៦១លាននាក់ កើនឡើងប្រមាណ ៦,៦០% និងភ្ញៀវទេសចរជាតិ មានចំនួនប្រមាណ ១១,៣០លាននាក់ កើនឡើងប្រមាណ ២,៣០% បើធៀបនឹងឆ្នាំ២០១៨ និងបានបង្កើតការងារដោយផ្ទាល់ដល់ប្រជាជនកម្ពុជា មានប្រមាណជាង ៦៣ម៉ឺននាក់។ ចំណូលពីវិស័យទេសចរណ៍ បានប្រមាណ ៤ ៩១៩លានដុល្លារអាមេរិក កើនឡើង ១២,៤០% ហើយចំណូលពីការលក់បណ្ណចូលទស្សនារមណីយដ្ឋានអង្គរទទួលបានប្រមាណជាង ៩៩លានដុល្លារអាមេរិក និងមានភ្ញៀវទេសចរអន្តរជាតិចូលទស្សនា ប្រមាណជាង ២,២លាននាក់។ នេះសបញ្ជាក់ឱ្យឃើញពីការរក្សាបាននូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងសន្តិភាពនៅទូទាំងប្រទេស ដោយអនុវត្តនូវវិធានការច្បាប់ដ៏ម៉ឺងម៉ាត់របស់រាជរដ្ឋាភិបាល។

ចំពោះការងារការបរទេសវិញ រាជរដ្ឋាភិបាលបានខិតខំបំពេញបេសកកម្មការទូតនៅលើឆាកអន្តរជាតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិលើគ្រប់វិស័យ ដោយទទួលបាននូវលទ្ធផលប្រកបដោយផ្លែផ្កា ជាអាទិ៍ វេទិកាខ្សែក្រវាត់និងផ្លូវលើកទី២ សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ នៅទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន សន្និសីទអន្តរជាតិលើកទី២៥ ស្តីពីអនាគតរបស់អាស៊ី នៅទីក្រុងតូក្យូ ប្រទេសជប៉ុន កិច្ចប្រជុំត្រួតពិនិត្យឡើងវិញជាសកលលើកទី៧ ស្តីពីជំនួយសម្រាប់ពាណិជ្ជកម្មក្រោមមូលបទ «ការគាំទ្រពិពិធកម្ម

និងការលើកកម្ពស់សេដ្ឋកិច្ចសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្នតាមរយៈជំនួយសម្រាប់ពាណិជ្ជកម្ម» និងចូលរួមព្រឹត្តិការណ៍ផ្សេងៗ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស និងកិច្ចប្រជុំកំពូលអាស៊ីប៉ាស៊ីហ្វិក ឆ្នាំ២០១៩-កម្ពុជា នៅរាជធានីភ្នំពេញ ហើយនៅឆ្នាំ២០២០នេះ ព្រះរាជាណាចក្រកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី១៣។ គិតចាប់តាំងពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១៩ គឺជាឆ្នាំទី១៣ ដែលព្រះរាជាណាចក្រកម្ពុជាបានបញ្ជូនកម្លាំងកងយោធពលខេមរភូមិន្ទទៅចូលរួមបំពេញបេសកកម្មក្សាសន្តិភាពក្រោមឆត្របស់អង្គការសហប្រជាជាតិសរុប ៦ ៥៥៧នាក់(ស្រី៣៣៨នាក់) មានជាអាទិ៍ សាធារណរដ្ឋស៊ូដង់ខាងត្បូង សាធារណរដ្ឋស៊ូដង់ សាធារណរដ្ឋលីបង់ សាធារណរដ្ឋឆាដ សាធារណរដ្ឋស៊ីប សាធារណរដ្ឋម៉ាលី សាធារណរដ្ឋយេម៉ែន និងសាធារណរដ្ឋអាហ្វ្រិកកណ្ដាល។

ព្រះរាជាណាចក្រកម្ពុជា ក៏ដូចបណ្ដាប្រទេសនៅលើពិភពលោកបាននិងកំពុងទទួលរងផលប៉ះពាល់ជាសាកលពីមេរោគកូវីដ ១៩ (COVID 19) ការឆ្លងរាលដាលនៃជំងឺនេះកំពុងមានសភាពធ្ងន់ធ្ងរ និងមិនទាន់មានសញ្ញាថមថយនៅឡើយ។ ប្រឈមនឹងផលវិបាកដោយសារមេរោគកូវីដ ១៩នេះ រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការចាំបាច់ និងបន្ទាន់ជាបន្តបន្ទាប់ ដើម្បីធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងជួយសម្រាលបន្ទុកប្រជាជនប្រកបមុខរបរក្នុងវិស័យរងផលប៉ះពាល់ ជាអាទិ៍ វិស័យទេសចរណ៍ និងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ ស្បែកជើងនិងកាបូបជាដើម។ រាជរដ្ឋាភិបាលក៏បានសម្រេចបិទជាបណ្ដោះអាសន្ននូវគ្រឹះស្ថានសិក្សារដ្ឋ និងឯកជនគ្រប់កម្រិត ការប្រគុំតន្ត្រី ការជួបជុំលក្ខណៈសាសនា រោងភាពយន្ត ក្លឹបកម្សាន្ត និងខារ៉ាអូខេផងដែរ ដើម្បីបង្ការ និងទប់ស្កាត់ការឆ្លងរាលដាល និងបានបង្កើតគណៈកម្មការជាតិប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ ១៩ ដឹកនាំផ្ទាល់ដោយទូលព្រះបង្គំជាខ្ញុំនាយករដ្ឋមន្ត្រី ព្រមទាំងបានបង្កើតក្រុមគ្រូពេទ្យស្ម័គ្រចិត្តសម្ដេចតេជោប្រយុទ្ធប្រឆាំងជំងឺកូវីដ ១៩។ រាជរដ្ឋាភិបាលបានណែនាំដល់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្តឱ្យកំណត់ទីតាំងដាក់ណាក់ ដូចជាសណ្ឋាគារ ផ្ទះសំណាក់ និងមជ្ឈមណ្ឌលបណ្ដុះបណ្ដាលដែលមានប្រព័ន្ធទឹក ភ្លើង គ្រែស្រាប់ ឬសាលារៀនក្នុងករណីមិនអាចរកទីតាំងសមរម្យបាន ដើម្បីត្រៀមទទួល និងព្យាបាលអ្នកជំងឺកូវីដ ១៩។

រាជរដ្ឋាភិបាលកំពុងបន្តតាមដានការវិវត្តនៃការឆ្លងរាលដាលនៃមេរោគកូវីដ ១៩នេះ និងបានត្រៀមលក្ខណៈរួចជាស្រេចក្នុងការចាត់វិធានការចាំបាច់ និងបន្ទាន់ជាបន្តបន្ទាប់បន្ថែមទៀត ដើម្បីការពារ និងពិនិត្យព្យាបាលជូនដល់ប្រជាជនឱ្យបានទាន់ពេលវេលា។ ឆ្លៀតឱកាសនេះ រាជរដ្ឋាភិបាលសូមអំពាវនាវដល់បងប្អូនប្រជាជននៅទូទាំងប្រទេស ឱ្យបន្តអនុវត្តវិធានការថែរក្សាអនាម័យសុខភាពឱ្យបានខ្ជាប់ខ្ជួន ចូលរួមសហការឱ្យបានល្អជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ជឿជាក់លើសមត្ថភាពនិងវិធានការរបស់រាជរដ្ឋាភិបាល និងមកទទួលការពិនិត្យព្យាបាលឱ្យបានទាន់ពេលវេលា ក្នុងករណីសង្ស័យថាមានរោគសញ្ញាជំងឺកូវីដ ១៩។ រាជរដ្ឋាភិបាលមានជំនឿយ៉ាងមុតមាំថា យើងនឹងឆ្លងផុតដំណាក់កាលដ៏លំបាកនេះ នាពេលឆាប់ៗខាងមុខ។

សម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្ដេចព្រះសង្ឃរាជ សម្ដេចព្រះរាជាគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ សម្ដេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្ដម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជាទីមេត្រី បងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា

រាល់សមិទ្ធផលដែលរាជរដ្ឋាភិបាលសម្រេចបានកន្លងទៅនេះ គឺអាស្រ័យដោយមានការដឹកនាំខាងនយោបាយត្រឹមត្រូវ ប្រកបដោយឆន្ទៈមោះមុត មានការចូលរួមគាំទ្រពីសមាជិក សមាជិកានៃស្ថាប័ន

នីតិប្បញ្ញត្តិ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា សមាជិក សមាជិការាជរដ្ឋាភិបាល មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ កម្មករ កសិករ និយោជិត ធុរជន វិនិយោគិន យុវជន យុវនារី លោកគ្រូ អ្នកគ្រូ គ្រូពេទ្យ និស្សិត សិស្សានុសិស្ស ក្នុងការបំពេញភារកិច្ចរបស់ខ្លួន និងការគាំទ្រយ៉ាងពេញទំហឹងពីប្រជាជនទូទាំងប្រទេស ព្រមជាមួយនឹងការជួយឧបត្ថម្ភគាំទ្រដោយចិត្តស្មោះសពីបណ្តាប្រទេសជាមិត្ត ដៃគូអភិវឌ្ឍ និងសហគមន៍អន្តរជាតិផងដែរ។

សម្រាប់ឆ្នាំថ្មី ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានឹងខិតខំពុះពារគ្រប់បែបយ៉ាងជាបន្តទៀត ដើម្បីបន្តថែរក្សាការពារសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ឱ្យបានកាន់តែរឹងមាំ ការពាររដ្ឋធម្មនុញ្ញ ការពាររបបរាជានិយម ស្របតាមបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ និងការពាររាល់សមិទ្ធផលដែលរាជរដ្ឋាភិបាលនិងប្រជាពលរដ្ឋទាំងមូលសម្រេចបាននាពេលកន្លងទៅ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងបន្តការធ្វើកំណែទម្រង់រដ្ឋដ៏ស៊ីជម្រៅតាមអភិក្រម «ឆ្លុះកញ្ចក់ ងូតទឹក ដុះក្អែល ព្យាបាល និងវះកាត់» ក្នុងនោះមានការពង្រឹងអភិបាលកិច្ចល្អ តាមរយៈការពង្រឹងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការធ្វើកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់ប្រព័ន្ធយុត្តិធម៌និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ការអភិវឌ្ឍធនធានមនុស្ស ការកែលម្អប្រព័ន្ធអប់រំឱ្យកាន់តែមានគុណភាពខ្ពស់ ដោយផ្សារភ្ជាប់ជាមួយសេដ្ឋកិច្ចឌីជីថលបដិវត្តន៍ឧស្សាហកម្មទី៤ ទីផ្សារការងារទាំងក្នុងនិងក្រៅប្រទេស ការលើកកម្ពស់ប្រព័ន្ធគាំពារសង្គម ការលើកកម្ពស់គុណភាពសេវាសុខាភិបាល និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសំណង់ ផ្លូវ ស្ពាន និងជាពសាស្ត្រ បង្កើនប្រភពថាមពលអគ្គិសនី បន្តពង្រីកបណ្តាញចែកចាយថាមពលអគ្គិសនីឱ្យបានគ្របដណ្តប់នៅទូទាំងប្រទេស ជាពិសេសនៅតាមប៉ូលសេដ្ឋកិច្ចសំខាន់ៗ អភិវឌ្ឍវិស័យឧស្សាហកម្ម សិប្បកម្ម សេវាកម្មដឹកជញ្ជូន ពាណិជ្ជកម្ម ទេសចរណ៍ និងវិស័យកសិកម្ម ឱ្យកាន់តែរីកចម្រើនឥតឈប់ឈរថែមទៀត។

ឆ្លៀតក្នុងឱកាសនេះដែរ ទូលបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមអរគុណបងប្អូនជនរួមជាតិដែលបានគាំទ្រដល់សារនយោបាយរបស់ទូលបង្គំ ខ្ញុំព្រះករុណា ខ្ញុំគឺ «**អរគុណសន្តិភាព**» ដែលមានតម្លៃមិនសាបសូន្យមិនថាកន្លងមក ថ្ងៃនេះ និងថ្ងៃក្រោយ។ មនុស្សទាំងអស់គ្នាត្រូវការសន្តិភាព លើកលែងតែពួកគេវេករប៉ុណ្ណោះដែលចង់បំផ្លាញសន្តិភាព។ «**អរគុណសន្តិភាព**» បានក្លាយទៅជាពាក្យស្លោករបស់ប្រជាជនដែលស្រឡាញ់សន្តិភាព។

សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជ សម្តេចព្រះរាជាគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជាទីមេត្រី បងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា

ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ នេះ ក្នុងនាមរាជរដ្ឋាភិបាលនិងក្នុងនាមទូលបង្គំជាខ្ញុំ ព្រមទាំងមន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងបងប្អូនជនរួមជាតិទាំងអស់ ទូលបង្គំជាខ្ញុំ សូមលំឱនកាយវាចាចិត្ត គោរពបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបីវត្ថុស័ក្តិសិទ្ធក្នុងលោក ទេវតាឆ្នាំថ្មី ព្រះនាម **គោរាគទេវី** សូមប្រោះព្រំសព្ទសាធុការពរ បវរមហាប្រសើរ ចំពោះព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល សូមព្រះអង្គមានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីបានគង់ប្រថាប់នៅក្នុងព្រះបរមសិរីរាជសម្បត្តិ ជាម្លប់ដ៏ត្រជាក់នៃប្រជាពលរដ្ឋខ្មែរ ជាកូន ជាចៅ ចៅទួត ជានិច្ចនិរន្តរ៍តរៀងទៅ។

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនេះដែរ ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងក្នុងនាមទូលបង្គំ ខ្ញុំព្រះករុណា សូមប្រគេនព្រះពរចំពោះសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជ សម្តេចព្រះរាជាគណៈ និងព្រះសង្ឃគ្រប់ព្រះអង្គ សូមមានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា មានព្រះសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីបានគង់ប្រថាប់ជាម្លប់របស់ពុទ្ធបរិស័ទក្នុងព្រះរាជាណាចក្រកម្ពុជាជានិច្ចនិរន្តរ៍តរៀងទៅ។

សូមជូនពរដល់ជនរួមជាតិខ្មែរគ្រប់រូបដែលកំពុងរស់នៅក្នុងនិងក្រៅប្រទេស មន្ត្រីរាជការ នាយទាហាន ពលទាហាននៃកងយោធពលខេមរភូមិន្ទ ដែលបាននិងកំពុងបំពេញភារកិច្ចការពារអធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងកំពុងបំពេញបេសកកម្មរក្សាសន្តិភាពនិងមនុស្សធម៌នៅក្រៅប្រទេស នាយនគរបាល ពលនគរបាលដែលបាននិងកំពុងរួមចំណែកការពារបូរណភាពទឹកដីនិងថែរក្សាការពារសន្តិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៃមាតុភូមិ លោកគ្រូ អ្នកគ្រូ គ្រូពេទ្យ ក្មួយៗសិស្សានុសិស្ស និស្សិត យុវជន យុវនារី កម្មករ កសិករ និយោជិត ធុរជន និងវិនិយោគិនដែលកំពុងប្រកបធុរកិច្ចនៅលើទឹកដីកម្ពុជា សូមទទួលបាននូវភាពជោគជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខ និងសូមបួងសួងដល់វត្ថុសក្តិសិទ្ធក្នុងលោក សូមជួយថែរក្សាប្រជាពលរដ្ឋខ្មែរ ដែលរស់នៅក្នុងស្រុក និងក្រៅស្រុកទាំងអស់ សូមឱ្យរួចផុតពីជំងឺកូវីដ ១៩នេះ។

សូមទេវតាឆ្នាំថ្មី ព្រះនាម **គោរាគទេវី** ជួយអភិបាលគ្រប់គ្រង ជួយបីបាច់ថែរក្សាគាំពារ និងប្រសិទ្ធពរជ័យដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ឱ្យមានសមានចិត្តជាកុសល យោគយល់គ្នា រួបរួមសាមគ្គីគ្នាជាមហាគ្រួសារខ្មែរតែមួយនៅលើទឹកដីមាតុភូមិអង្គរជាទីស្នេហា ដោយសេចក្តីសុខក្សេមក្សាន្តនិងប្រកបដោយកិត្តិយស សេចក្តីថ្លៃថ្នូរ ក្នុងឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ អព្យាក្រឹត និងវឌ្ឍនភាពសង្គមតរៀងទៅ។

*សូមអរព្រះគុណនិងអរគុណ!*

ថ្ងៃពុធ ៩ កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មេសា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**